## Introducing oneself to others



អ្នកជាបុគ្គលិកថ្មីនៅក្រុមហ៊ុនមួយ តើអ្នកត្រូវណែនាំខ្លួនឯងយ៉ាងដូចម្តេចខ្លះ?

បញ្ញា៖ ជម្រាបសួរ ខ្ញុំឈ្មោះ បញ្ញា។

វុទ្ធី៖ ជម្រាបសួរ។ រកអ្នកណាគេមែន?

បញ្ញា៖ អត់ទេ ខ្ញុំបុគ្គលិកថ្មី ទើបតែចូលធ្វើការថ្ងៃហ្នឹង។ ខ្ញុំនៅផ្នែកទីផ្សារ។

វុទ្ធី៖ អូ ខ្ញុំឈ្មោះ វុទ្ធី។ ខ្ញុំនៅផ្នែកទីផ្សារដែរទេតើ! នេះ ធារី នៅផ្នែកគណនេយ្យ។

ធារី៖ រីករាយដែលបានស្គាល់។ អង្គុយលេងសិនទៅ។ តិចទៀត បងសុខុម (ប្រធានផ្នែកទីផ្សារ) មកហើយ។

បញ្ញា៖ បាទ អរគុណបង។

| | |
|---|---|
| បញ្ញា / សុខុម | Cambodian names that can be used for both male and female |
| បុគ្គលិក | staff, employee |
| ក្រុមហ៊ុន | company |
| រកអ្នកណាគេមែន? | Are you looking for someone? |
| ផ្នែកទីផ្សារ | marketing division (in a company) |
| ផ្នែកគណនេយ្យ | accounting division |
| អង្គុយលេងសិនទៅ | Please have a seat! |
| តិចទៀត | shortly, in a few minutes |
| ប្រធាន | head (of a division / team) |

## Cultural notes

នៅប្រទេសកម្ពុជា ការណែនាំខ្លួនឯងចំពោះមនុស្សទើបតែជួបគ្នាដំបូង ផ្តើមឡើងដោយពាក្យថា សួស្តី (អាយុប្រហែលគ្នា មិនចាំបាច់លើកដៃសំពះទេ) ឬពាក្យថា ជម្រាបសួរ (អាយុមើលទៅច្រើនជាងគួរលើកដៃសំពះផងដែរ)។ បន្ទាប់មក ភាគច្រើនណែនាំខ្លួនដោយខ្លីបំផុត គឺគ្រាន់តែប្រាប់ឈ្មោះតែប៉ុណ្ណោះ (ករណីណែនាំខ្លួនទៅកាន់មនុស្សតែម្នាក់ ឬតិចនាក់ ហើយពេលវេលាតិច) ឬក៏បន្ថែមដោយស្រុកកំណើត និងមុខរបរសព្វថ្ងៃ គឺថា ខ្ញុំឈ្មោះ ... ស្រុកកំណើតនៅ ... រាល់ថ្ងៃរៀន/ធ្វើការនៅ ...

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

(ករណីណែនាំខ្លួនទៅកាន់មនុស្សច្រើន ឬគេឲ្យពេលវេលាច្រើនសម្រាប់ណែនាំ)។
គឺថាយើងមិនចាំបាច់ត្រូវរៀបរាប់ព័ត៌មានច្រើនអំពីខ្លួនឯងតាំងពីដំបូងឡើយ
គឺរង់ចាំឆ្លើយនឹងសំណួររបស់គូសន្ទនា ដូចជា

— ផ្ទះនៅណាដែរ?
— អាយុប៉ុន្មានហើយ? (ដើម្បីដឹងថាអាយុបងឬប្អូន)
— ចំណង់ចំណូលចិត្តអីគេ?

ជាដើម។ ចំពោះការណែនាំខ្លួននៅកន្លែងធ្វើការ ភាគច្រើន យើងតែងតែប្រាប់ឈ្មោះផ្នែកដែលខ្លួននៅ
បន្ទាប់ពីប្រាប់ឈ្មោះ គឺថា ខ្ញុំឈ្មោះ ... នៅផ្នែក ...។

| | |
|---|---|
| ករណី | in case of |
| ស្រុកកំណើត | birthplace, home town |
| មុខរបរ | job, profession |
| រៀបរាប់ព័ត៌មាន | to give information |
| គូសន្ទនា | conversation partner |
| កន្លែងធ្វើការ | workplace |
| ផ្នែក | division, department (of a company) |

## Additional dialogue

សុខុម៖ អូ បញ្ញាមែន? ម៉ោ ម៉ោនេះបងប្រាប់។
បញ្ញា៖ បាទបង។
សុខុម៖ នេះតុធ្វើការរបស់បញ្ញាឯង។ ក្រុមយើងត្រូវចេញទៅក្រៅជួបភ្ញៀវច្រើន
ហើយត្រូវគិតរកវិធីសាស្ត្រធ្វើម៉េចឲ្យគេស្គាល់ក្រុមហ៊ុនយើងកាន់តែច្រើន។
បញ្ញា៖ បាទបង។
សុខុម៖ យើងកំពុងធ្វើគម្រោងមួយ។ ហើយបងចង់ឲ្យបញ្ញាឯងកាន់តួនាទីមួយ។

| | |
|---|---|
| ម៉ោ | spoken form of មក |
| name + ឯង | more polite way to say “you” |
| តុធ្វើការ | desk |
| គិតរក | to think about, to figure out |
| វិធីសាស្ត្រ | strategy, method |
| គម្រោង | project |
| កាន់តួនាទី | to take on responsibility |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.